**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣៣៧ ព្ររ.៣.២៤-៩៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបមក**

លោក ប្រធានតុលាការ ខេត្តរតនគីរី

**សូមជ្រាប**

**កម្មវត្ថុ:** អំពីបទល្មើសព្រៃឈើដែលជាប់ពាក់ព័ន្ធនិងពន្ធសមាមាត្រ ។

**យោង:** លិខិតលេខ ២១-៩៧-រប ចុះថ្ងៃទី១២-០២-៩៧ របស់តុលាការ ខេត្តរតនគិរី ។

ខ្ញុំសូមជម្រាបលោកប្រធានថា បញ្ហាបង់ពន្ធសមាមាត្រក្នុងបទល្មើសព្រៃឈើដែលតុលាការខេត្តរតនគិរីបានសម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ០៨ ចុះថ្ងៃទី២៥-០៣-៩៥ បានសម្រេចរឹបអូសឈើប្រភេទលេខ ២ ចំនួន១១,៧១១,៧០០ម៉ែត្រគូប របស់ឈ្មោះ.....កាតំណាងក្រុមហ៊ុន.....ជាទ្រព្យសម្បត្តិរដ្ឋ ។ដូច្នេះអ្នកដែលត្រូវយកសាលក្រមចូលជាស្ថាពរនេះនៅអនុវត្តចាត់ចែងលក់ឡាយឡុងឈើនោះ យកប្រាក់បញ្ចូលជាថវិការដ្ឋគឺជាសមត្ថកិច្ចរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់នៃក្រសួងកសិកម្ម ពុំមែនជាសមត្ថកិច្ចរបស់តុលាការទេ ។ ម៉្យាងទៀតពន្ធសមាមាត្រច្បាប់តម្រូវអោយភាគីចាញ់ក្តីរឿងរដ្ឋប្បវេណី បង់ពន្ធសមាមាត្រនេះចូលថវិការដ្ឋនិងជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ហើយពុំមានចែង អោយភាគីក្នុងរឿងក្តីព្រហ្មទណ្ឌបង់ពន្ធសមាមាត្រទេ ។

ដើម្បីធានាការអនុវត្តសាលក្រមខាងលើនេះ ឱ្យមានប្រសិទ្ធិភាពតាមសមត្ថកិច្ចនោះសូមលោកប្រធានពិនិត្យឡើងវិញនូវសារាចរណែនាំលេខ ០២ សរ-៦១៣-៨៨ ចុះថ្ងៃទី០១-០៤-៨៨ របស់ក្រសួងយុត្តិធម៌ និងច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍
-តុលាការនិងអយ្យការខេត្ត ក្រុង
-ដើម្បីជ្រាបនិងអនុវត្ត